**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | |
|---|---|
| សំណុំរឿងលេខ៖ | ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៥) |
| ភាគីដាក់ឯកសារ៖ | មេធាវីការពារក្តីរបស់ មាស មុត |
| ដាក់ជូន៖ | សហចៅក្រមស៊ើបអង្កេត |
| ភាសាដើម៖ | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០២១ |

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 04-May-2021, 08:40
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

| | |
|---|---|
| ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ | **សាធារណៈ** |
| ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ | **សាធារណៈ**/Public |
| ចំណាត់ថ្នាក់ប្រភេទឯកសារ៖ | |
| ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖ | |
| ឈ្មោះមន្ត្រីកត់ត្រា៖ | |
| ហត្ថលេខា៖ | |

---

**សំណើបន្ទាន់របស់ មាស មុត សុំពន្យារពេលចម្លើយរបស់ខ្លួនតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅកាន់សហចៅក្រមស៊ើបអង្កេត សុំឱ្យបញ្ជូនសំណុំរឿង០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង**

---

**ដាក់ដោយ** ÷

**សហមេធាវី** ៖

អាង ឧត្តម

Michael G. KARNAVAS

**ផ្ញើជូន** ÷

**សហចៅក្រមស៊ើបអង្កេត៖**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS

**ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តី ០០៣**

លោក មាស មុត តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") ស្នើសុំជាបន្ទាន់ ពន្យារពេលមួយសប្តាហ៍សម្រាប់ចម្លើយរបស់គាត់ តបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅកាន់សហចៅក្រមស៊ើបអង្កេត ("ស.ច.ស.") សុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ("សំណើរបស់ ស.ព.អ.")[1]។ សំណើនេះ ត្រូវបានធ្វើឡើងជាចាំបាច់ ដើម្បីអនុញ្ញាតឱ្យមានពេលវេលាគ្រប់គ្រាន់ឆ្លើយតបដោយសមហេតុផល និង ទូលំទូលាយ ទៅនឹងបញ្ហាដែលលើកឡើងដោយអង្គបុរេជំនុំជម្រះ ("អ.ប.ជ.") នៅក្នុងសេចក្តីពិចារណារបស់ អ.ប.ជ. នៅក្នុងរឿងក្តី ០០៣ និង ស.ព.អ. នៅក្នុងសំណើរបស់គាត់។ ដោយសារតែភាពបន្ទាន់នៃសំណើនេះ មេធាវីការពារក្តីស្នើសុំដាក់សំណើនេះជាភាសាអង់គ្លេសជាមុន ដោយសំណៅបកប្រែជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយ។

## I. **សាវតារ**

១. អ.ប.ជ. បានចេញសេចក្តីពិចារណារបស់ខ្លួន នៅក្នុងរឿងក្តី ០០៣ នៅថ្ងៃទី ៧ ខែមេសា ឆ្នាំ២០២១ ដោយប្រកាសជាឯកច្ឆ័ន្ទថា "ការចេញដីកាដំណោះស្រាយពីរ ដែលផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺជាការខុសច្បាប់ ដោយរំលោភបំពានទៅលើក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក."[2]។ អ.ប.ជ. មិនអាចរកសំឡេងភាគច្រើនលើសលប់ដែលតម្រូវ ដើម្បីឈានដល់ការធ្វើសេចក្តីសម្រេចរួមមួយលើអង្គសេចក្តីបានឡើយ ហើយបានភ្ជាប់នូវមតិយោបល់ដោយឡែកពីគ្នារបស់ចៅក្រមជាតិ និង ចៅក្រមអន្តរជាតិ នៃ អ.ប.ជ.[3]។

២. ចៅក្រមជាតិនៃ អ.ប.ជ. បានពិចារណាថា គប្បីបញ្ជូនសំណុំរឿង ០០៣ "ទៅតម្កល់ទុកនៅបណ្ណសារនៃ អ.វ.ត.ក." ព្រោះ ស.ច.ស. ទាំងពីរ មានឋានៈស្មើគ្នា ហើយយោងតាមអញ្ញត្រកម្មនៃសច្ចាធារណ៍និរទោស "ពុំអនុញ្ញាតឱ្យអង្គបុរេជំនុំជម្រះ សម្រេចថា កិច្ចរបស់សហចៅក្រមស៊ើបអង្កេតណាម្នាក់ មានឧត្តមភាពនោះទេ"[4]។

---

[1] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅកាន់សហចៅក្រមស៊ើបអង្កេត សុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០២១ ដែលបានជូនដំណឹងជាភាសាអង់គ្លេស និងភាសាខ្មែរ នៅថ្ងៃទី ២៥ ខែមេសា ឆ្នាំ ២០២១ ឯកសារ D270 ("សំណើរបស់ ស.ព.អ.")។

[2] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០២១ ឯកសារ D266/27 & D267/35 ("សេចក្តីពិចារណាក្នុងរឿងក្តី ០០៣") ទំព័រ ៥៦។

[3] សេចក្តីពិចារណាក្នុងរឿងក្តី ០០៣ ទំព័រ ៥៥។

[4] *ដូចខាងលើ* កថាខណ្ឌ ១១៥-១១៨។

៣. ចៅក្រមអន្តរជាតិនៃ អ.ប.ជ. បានពិចារណាថា សំណុំរឿង ០០៣ ត្រូវតែបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង ព្រោះដីកាសម្រេចលើកលែងចោទប្រកាន់ "ត្រូវបានចាត់ទុកជាមោឃៈ និង គ្មានសុពលភាព ដោយហេតុថាជាឯកសារគតិយុត្តិមិនពេញលេញ" ហើយ"មានការសម្រេចជាឯកច្ឆន្ទ *តាមព្រឹត្តន័យ*" ដោយ អ.ប.ជ. ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព ហើយដោយត្រូវបានជូនដំណឹងតាមវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុងអំពីសេចក្ដីពិចារណានេះ ហេតុដូច្នេះ ស.ច.ស. ត្រូវតែ "បន្តកិច្ចនីតិវិធីជាបន្ទាន់" ស្របតាមសេចក្ដីសម្រេចតាមសំឡេងជាឯកច្ឆ័ន្ទរបស់ អ.ប.ជ.[5]។

៤. នៅថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០២១ ស.ព.អ. បានស្នើសុំទៅកាន់ ស.ច.ស. ឲ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង "ដើម្បីអនុវត្តការព្រមព្រៀងជាឯកច្ឆ័ន្ទរបស់ចៅក្រម អ.ប.ជ. ដែលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃរឿងក្ដី ០០៣ មានសុពលភាព"[6]។ សំណើរបស់ ស.ព.អ. ត្រូវបានជូនដំណឹងនៅថ្ងៃទី ២៥ ខែមេសា ឆ្នាំ ២០២១ ដែលធ្វើឲ្យកាលបរិច្ឆេទកំណត់សម្រាប់ចម្លើយគឺនៅត្រឹមថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០២១[7]។

## II. ច្បាប់ និង ទន្លឹករណ៍

៥. លោក មាស មុត មានសិទ្ធិក្នុងការដាក់ចម្លើយ*ប្រកបដោយប្រសិទ្ធិភាព*[8]។ ជាទូទៅ ការណ៍នេះមានន័យថា ត្រូវផ្ដល់ដល់លោក មាស មុត នូវពេលវេលា និង មធ្យោបាយគ្រប់គ្រាន់ សម្រាប់ការរៀបចំ

---

[5] *ដូចខាងលើ* កថាខណ្ឌ ៣៤២-៣៤៣។

[6] សំណើរបស់ ស.ព.អ. កថាខណ្ឌ ២។

[7] សារអេឡិចត្រូនិកពី ឆាយ ច័ន្ទលីដា ចំណងជើង "កាលបរិច្ឆេទកំណត់" ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០២១ (ឯកសារភ្ជាប់ ១)។

[8] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង ក្របខណ្ឌ អ.វ.ត.ក. ដែលបញ្ចូលនូវបទដ្ឋានយុត្តិធម៌អន្តរជាតិនៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានធានាថាជនត្រូវចោទ និង ជនជាប់ចោទ ត្រូវទទួលបានសិទ្ធិដាក់សារណា*ប្រកបដោយប្រសិទ្ធិភាព*។ *សូមមើល* មាត្រា ៣១, ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ១៩៩៣ ដែលធ្វើវិសោធនកម្មដោយក្រមចុះថ្ងៃទី ៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើប្រាស់វិសោធនកម្មមាត្រា ១១, ១២, ១៣, ១៨, ២២, ២៦, ២៨, ៣០, ៣៤, ៥១, ៩០, ៩១, ៩៣ និង មាត្រាដទៃទៀតនៃជំពូក៨ ដល់ ១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តដោយរដ្ឋសភា កាលពីថ្ងៃទី ៤ ខែមីនា ឆ្នាំ១៩៩៩ ("រដ្ឋធម្មនុញ្ញកម្ពុជា")។ មាត្រា ១២(២), ១៣(១) នៃកិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក.។ មាត្រា ៣៣ ថ្មី ៣៥ថ្មី(ខ) ៣៥ថ្មី(ខ) និង (ឃ) នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក.។ វិធាន ២១(១) នៃវិធានផ្ទៃក្នុង។ មាត្រា ១៤(៣)(ខ) និង (ឃ) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុម័តថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៦៦ ចូលជាធរមានថ្ងៃទី ២៣ ខែមីនា ឆ្នាំ១៩៧៦ 999 U.N.T.S. 171 ("កតិកាសញ្ញា ICCPR")។ *សូមមើលផងដែរ រឿងក្ដី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អវតក/កសច (អ.បជ.៥៨) សេចក្ដីសម្រេចលើសំណើរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសុំពន្យារយៈពេលកំណត់និងចំនួនទំព័រ ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១៨ ឯកសារ D362/4

ការការពារខ្លួនរបស់គាត់ និង មានសហមេធាវី ដែលមានសមត្ថភាពបំពេញកិច្ចគ្រប់យ៉ាងដោយការយកចិត្តទុកដាក់ ក្នុងការការពារសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់គាត់[9]។ ជាពិសេស នៅក្នុងករណីនេះ នេះមានន័យថា ត្រូវផ្តល់ពេលវេលា និង មធ្យោបាយគ្រប់គ្រាន់ដល់លោក មាស មុត ដើម្បីដាក់ចម្លើយរបស់គាត់តបទៅនឹងសំណើរបស់ ស.ព.អ.។ ជាការគួរឲ្យភ្ញាក់ផ្អើល កាលបរិច្ឆេទកំណត់ចំនួន ១០ ថ្ងៃ សម្រាប់ចម្លើយ តាមសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក. ("សេចក្តីណែនាំអនុវត្ត")[10] គឺមានរយៈពេលខ្លីមែនទែន ដែលមិនអាចឲ្យលោក មាស មុត ផ្តល់នូវចម្លើយប្រកបដោយប្រសិទ្ធិភាពបានឡើយ ដោយសារតែភាពស្មុគ្រស្មាញនៃបញ្ហា ដែលលើកឡើងដោយសេចក្តីពិចារណារបស់ អ.ប.ជ.។

៦. ដើម្បីបំពេញករណីកិច្ចតាមបែបសីលធម៌ និង វិជ្ជាជីវៈរបស់ខ្លួន ប្រកបដោយការយកចិត្តទុកដាក់ក្នុងការការពារសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក មាស មុត[11] និង ព្រាងចម្លើយប្រកបដោយប្រសិទ្ធិភាពនោះ មេធាវីការពារក្តីត្រូវតែត្រួតពិនិត្យ និង វិភាគលើរាល់ឯកសារសំខាន់ទាំងអស់ ដែលយោងដោយចៅក្រម អ.ប.ជ. នៅក្នុងសេចក្តីពិចារណារបស់ អ.ប.ជ. និង ដោយ ស.ព.អ. នៅក្នុងសំណើរបស់គាត់ ព្រមទាំងស្រាវជ្រាវច្បាប់ ពិនិត្យសំណុំរឿង សុំការណែនាំពីលោក មាស មុត ព្រមទាំងព្រាងទឡ្ហីករណ៍ដែលរឹងមាំ។ កិច្ចការទាំងអស់នេះ មិនអាចធ្វើទៅតាម

---

កថាខណ្ឌ ១០។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Stanišić & Župljanin* សំណុំរឿងលេខ IT-08-91-A សេចក្តីសម្រេចលើញត្តិរបស់ Mićo Stanišić's និង Stojan Župljanin ស្នើសុំការកែប្រែពេលវេលា និងចំនួនទំព័រ ក្នុងការដាក់សារណាបណ្តឹងសាទុក្ខ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៣ ទំព័រ ២, ៤។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Sainović និងជនផ្សេងទៀត* សំណុំរឿងលេខ IT-05-87-A សេចក្តីសម្រេចលើសំណើរួមសុំពន្យាពេលវេលាដាក់សារណាឆ្លើយតប ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០០៩ ទំព័រ ៤។ *រឿងក្តី Marpa Zeeland B.V. & Metal Welding B.V. តទល់នឹង The Netherlands*, ECtHR App. No. 46300/99 ថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ ២០០៤ កថាខណ្ឌ ៥១។

[9] ការបំពេញកិច្ចដោយការយកចិត្តទុកដាក់ តម្រូវឲ្យសហមេធាវីរបស់ជនត្រូវចោទ ធ្វើអ្វីមួយ និង គ្រប់យ៉ាង ដើម្បីធានាបានថា គ្រប់សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ត្រូវបានផ្តល់ដោយពេលលេញដល់កូនក្តីរបស់ខ្លួន រួមទាំងធ្វើការតវ៉ាចាំបាច់ផ្នែកអង្គហេតុ និង អង្គច្បាប់ទាំងអស់ ដោយពិនិត្យមើលលើសច្ចភាព និងភាពត្រឹមត្រូវនៃភស្តុតាង ដែលសហចៅក្រមស៊ើបអង្កេតបានប្រមូល ហើយដែលត្រូវបានប្រើប្រាស់ប្រឆាំងជនជាប់ចោទនានា។ វិធាន ១.៣ នៃវិធានក្រមវិជ្ជាជីវៈអាឡាស្កា (ALASKA RULES OF PROF'L CONDUCT) (ឆ្នាំ ២០១៧-២០១៨) ។ *ដូចខាងលើ* មតិយោបល់ចំពោះវិធាន ១.៣។ *សូមមើលផងដែរ* មាត្រា ៧ នៃក្រមសីលធម៌មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ មាត្រា ៥៨ នៃច្បាប់ស្តីពីលក្ខន្តិកៈគណៈមេធាវី (ឆ្នាំ ១៩៩៥)។ វិធាន ២២(៤) នៃវិធានផ្ទៃក្នុង។

[10] មាត្រា ៨.៣ នៃសេចក្តីណែនាំអនុវត្ត។

[11] *សូមមើលខាងលើ* ជើងទំព័រ ៩។

បទដ្ឋានខ្ពស់បំផុតដែលចាំបាច់ ក្នុងការការពារសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក មាស មុត ក្នុងរយៈពេលកំណត់ តាមសេចក្តីណែនាំអនុវត្តបានឡើយ ដោយសារតែមេធាវីការពារក្តីមានកង្វះបុគ្គលិក[12]។

៧. ស.ច.ស. មានសិទ្ធិអំណាចតាមវិធាន ៣៩(២) នៃវិធានផ្ទៃក្នុង "កំណត់ពេលវេលា" សម្រាប់សារណា "ដោយគិតពិចារណាដល់កាលៈទេសៈនៃរឿងក្តី"។ តាមវិធាន ៣៩(៤)(ក) នៃវិធានផ្ទៃក្នុង ស.ច.ស. ក៏មានសិទ្ធិអំណាច "ពន្យារពេលវេលាកំណត់ ដែលខ្លួនបានកំណត់"។

៨. ការអនុញ្ញាតតាមសំណើសុំពន្យារពេលមួយសប្តាហ៍ដ៏សមស្របនេះ នឹងមិននាំឲ្យខូចប្រយោជន៍ដល់ភាគី ហើយក៏មិនពន្យារពេលដោយមិនសមហេតុផលនៅក្នុងនីតិវិធីនោះឡើយ ដោយសារតែភាពស្មុគ្រស្មាញនៃបញ្ហាដែលត្រូវធ្វើការសម្រេច។ ផ្ទុយទៅវិញ រយៈពេលបន្ថែមដែលបានស្នើឡើងនេះ នឹងអនុញ្ញាតឲ្យមេធាវីការពារក្តី ផ្តល់សារណាយ៉ាងល្អិតល្អន់ ជូន ស.ច.ស. លើបញ្ហាស្មុគ្រស្មាញ ដែលលើកឡើងដោយចៅក្រម អ.ប.ជ. និង ស.ព..អ.។

សូមលោកចៅក្រមទទួលយកសេចក្តីគោរពអំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២៩** ខែ**មេសា** ឆ្នាំ **២០២១**

**សហមេធាវីការពារក្តីលោក មាស មុត**

______________________ ______________________

អាង ឧត្តម Michael G. KARNAVA

[12] សំណើរបស់ មាស មុត ជូនអង្គភាពគាំពារការការពារក្តី សុំជ្រើសរើសទីប្រឹក្សាច្បាប់ជាន់ខ្ពស់ គឺកំពុងនៅស្ថិតក្នុងការរង់ចាំនៅឡើយ។ ក្រៅពីសហមេធាវី មេធាវីការពារក្តី មានតែអ្នកគ្រប់គ្រងសំណុំរឿង ដែលមានមូលដ្ឋាននៅទីក្រុងភ្នំពេញ និងទីប្រឹក្សាច្បាប់ជាន់ខ្ពស់ ដែលបំពេញការងារពីចម្ងាយ។